# រឿងនាងអសិតាភូ

(ចាក អ. ទុ.)

(ប្រាថ្នាហួសហេតុ នាំឱ្យអន្តរាយ)

កាល កន្លងទៅហើយ មានព្រះរាជបុត្រ ព្រះចៅពារាណសីមួយអង្គ ព្រះរាជបិតា មិនគាប់ព្រះរាជហឫទ័យ ទ្រង់បំបោះបង់ព្រះរាជនិវេសន៍ បាននាំព្រះរាជទេពី របស់ទ្រង់ព្រះនាមអសិតាភូចូលទៅក្នុងព្រៃហេមពាន្ត សោយត្រីសាច់និងផ្លែឈើ មើមឈើជាអាហារ ។ ព្រះនាងអសិតាភូ ជាព្រះទេពី ខំគោរពប្រតិបត្តិដោយបំរើ ដោយឥតមានធ្វេសប្រហែលឡើយ ។

ថ្ងៃមួយព្រះរាជបុត្រជាព្រះភស្តា របស់នាងបានឃើញកិន្នរីមានរូបឆោមល្អ ក៏លះ បង់ចោលព្រះនាងខំស្វះស្វែងទៅតាម កិន្នរីនោះ ។ ព្រះនាងគិតថាព្រះរាជបុត្រ មិនអើពើនឹងអញ ស៊ូទៅតាមនាងកិន្នរីវិញ ។ លុះគិតហើយក៏ចូលទៅរក តាបស ម្នាក់សុំរៀនចំរើនកសិណ មិនយូរប៉ុន្មានក៏បណ្តាលអោយអភិញ្ញាកើតឡើង ទើប មកនៅក្នុងបណ្ណសាលារបស់ខ្លួនវិញ ។

ព្រះរាជបុត្រនោះកាលបើរកផ្លូវ ទៅតាមនាងកិន្នរីមិនឃើញ ក៏អស់សង្ឃឹម ក៏ត្រឡប់មករកព្រះនាងវិញ ។ ព្រះនាងអសិតាភូ ឃើញព្រះរាជបុត្រយាងមកវិញ ក៏ហោះទៅអាកាសទៅនៅក្នុងទីដទៃបាត់ ។ ព្រះរាជបុត្រកាលបើព្រះទេពី លះ បង់លែងត្រូវការហើយក៏ ខ្សឹកខ្សួលទួញយំសង្រែងសង្រែថា ៖

អត្រិច្ឆំ អតិលោភេន អតិលោភមេតេន ច<br>ឯវំ ហាយតិ អត្ថម្ហា អហំវ អសិតាភុយា ។

សេចក្តីថា បុគ្គលដែលប្រាថ្នាហួសកំរិត ចង់បានខ្លាំងពេក ព្រោះស្រវឹងងប់ដោយ ចំណង់ រមែងសាបសូន្យចាកប្រយោជន៍យ៉ាងណា ខ្ញុំឯងកាលប្រាថ្នា ក៏ទៅជាអ្នក សាបសូន្យចាកព្រះទេពីឈ្មោះ អសិតាភូយ៉ាងនោះដែរ ។

ព្រះរាជបុត្រតាំងពីថ្ងៃនោះមក នៅក្នុងព្រៃតែម្នាក់ឯង លុះអស់ពីព្រះបិតាទៅ បាន សោយរាជ្យជាស្តេចស្នងអង្គ ព្រះរាជបិតា ។ គ្រានោះមានទេវតាមួយអង្គ បានសូត្រគាថាថ្វាយជាព្រះសណ្តាប់ថា ៖

អត្រិច្ឆំ អតិលោភេន អតិលោភមតេន ច
ឯវំ សោ ហាយតត្ថានំ ចន្ទំវ អសិតាភុយា ។

សេចក្តីថា បុគ្គលដែលប្រាថ្នាហួសកំរិត ចង់បានខ្លាំងពេកព្រោះស្រវឹងងប់ដោយចំណង់ បុគ្គលនោះតែងនាំឱ្យប្រយោជន៏ របស់ខ្លួនសាបសូន្យយ៉ាងនេះ ដូចជាព្រះរាជបុត្រកាលប្រាថ្នានូវ នាងកិន្នរី ឈ្មោះចន្ទាហើយ ជាអ្នកសាបសូន្យចាកព្រះទេពី ឈ្មោះអសិតាភូ ។

ព្រះរាជាទ្រង់អៀនខ្មាស ហើយតាំងព្រះទ័យលែងប្រព្រឹត្តយ៉ាងនេះតទៅទៀត ទ្រង់គ្រងរាជសម្បត្តិជាសុខក្សេមក្សាន្តដរាបទៅ ។

សូមអស់លោកអ្នកអនុមោទនា !

ចប់